# គម្រោងDOCKSIDE

## របាយការណ៍កាតាឡុកមុខវិជ្ជាសិក្សា

### អនុសាសន៍សំខាន់ៗ

ខែ ធ្នូ ឆ្នាំ ២០១៨

លោក ប្រាង់ស៊ីសស្កូ តួរេស សាកលវិទ្យាល័យ វីហ្គោ

លោកស្រី តាន់ សូលីដា សាកលវិទ្យាល័យ បាត់ដំបង

លោក វ៉ន ភីរុណ សាកលវិទ្យាល័យបាត់ដំបង

លោក កង សុវណ្ណារ៉ា សាកលវិទ្យាល័យជាតិ គ្រប់គ្រង

លោក លី សុខហេង សាកលវិទ្យាល័យជាតិ គ្រប់គ្រង

លោក  ឈឹម ចាយ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

លោកស្រី នាង ម៉ាលីន សាកលវិទ្យាល័យភូមិន្ទកសិកម្ម

លោក ឡូរ៉ង់ មេស្មាន សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

លោក ប៉ូល អង់ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

លោក លីយោណែល ឡឺមីញាល់ សាកលវិទ្យាល័យ ណង់

លោក ឌីវីន អាសាន់ សាកលវិទ្យាល័យ សាវធីន ដាណឺម៉ាក

Co-funded by the
Erasmus+ Programme
of the European Union

មាតិការ


១.សេចក្តីផ្តើម .................................................................................................................... 1

២.អនុសាសន៍សំខាន់ៗ ............................................................................................................. 2

៣កម្មវិធីសិក្សាថ្នាក់បណ្ឌិតជំនាញការគ្រប់គ្រងបរិស្ថាននិងធនធាន..................................................................... 5


## ១. សេចក្តីផ្តើម

ឯកសារនេះគូសបញ្ជាក់ពីអនុសាសន៍សំខាន់ៗ ដោយផ្អែកលើ របាយការណ៏កាតាឡុកនៃមុខវិជ្ជាសិក្សារបស់គម្រោង DOCKSIDE ដើម្បីសំរេចអោយបានជោគជ័យនូវកម្មវិធីសិក្សាថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតរួមគ្នារវាងសាកលវិទ្យាល័យនៅអ៊ឺរ៉ុប និងសាកលវិទ្យាល័យនៅកម្ពុជា។

អនុសាសន៍ទាំងនេះគឺផ្អែកទៅលើការស្ទង់មតិជាមួយ សាកលវិទ្យាល័យកម្ពុជាចំនួន ៤ និងសាកលវិទ្យាល័យនៅអ៊ឺរ៉ុបចំនួន ៣ ដែលចូលរួមក្នុងគម្រោងDOCKSIDE៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សាកលវិទ្យាល័យបាត់ដំបង សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យវីហ្គោ សាកលវិទ្យាល័យណង់ និងសាកលវិទ្យាល័យ សាវធឺន ដាណឺម៉ាក។

## ២. អនុសាសន៍សំខាន់ៗ

| |
|---|
| អនុសាសន៍ទីមួយ<br><br>ពង្រឹងកំរិតសិក្សាបរិញ្ញាបត្រហើយផ្សារភ្ជាប់វាទៅកាន់កំរិតបរិញ្ញាបត្រជាន់ខ្ពស់ |

ដោយសារតែត្រូវបង់ថ្លៃសាលា សិស្សភាគច្រើនដែលចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ គឺជាសិស្សដែលសិក្សាក្រៅម៉ោង ហើយដែលពួកគេមានបទពិសោធន៍ការងាររួចហើយមុនពេលត្រលប់ទៅកាន់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ដោយហេតុនេះហើយ ការភ្ជាប់ទំនាក់ទំនងរវាងបរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់នៅមានភាពទន់ខ្សោយ។ មួយវិញទៀត គោលនយោបាយដែលអនុញ្ញាតអោយនិស្សិតបន្តពីថ្នាក់បរិញ្ញាបត្រទៅកាន់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គួរតែត្រូវបង្កើតឡើង (ឧទាហរណ៍ តាមរយៈការផ្តល់អាហារូបករណ៍)។

| |
|---|
| អនុសាសន៍ទីពីរ<br><br>បង្កើតថ្នាក់បរិញ្ញាបត្រជំនាញ ហើយផ្សារភ្ជាប់វាទៅនឹងផ្នែកឯកជនដើម្បីទទួលបានអាហារូបករណ៍ និងការងារសំរាប់និស្សិត |

ផ្អែកលើព័ត៌មានរបស់យើងដែលទទួលបានពីទស្សនៈអំពីកាតាឡុកមុខវិជ្ជានៅក្នុងខែ កុម្ភៈ ឆ្នាំ២០១៨ ឃើញថាទំនាក់ទំនងជួយផ្នែក ឯកជននៅមានកំរិតខ្សោយ បើទោះបីជាភាគច្រើននៃនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សុទ្ធតែបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលអាជីពក្រៅម៉ោងក៏ដោយ។ ការធ្វើអោយកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្លាយជាបរិញ្ញាបត្រអាជីព អាចផ្តល់ជាប្រយោជន៍ដល់និស្សិត ក៏ដូចជាអាជីពការងាររបស់ពួកគេ។ ក្នុងន័យនេះ សាកលវិទ្យាល័យគួរតែបង្កើតអោយមានទំនាក់ទំនងរយៈពេលវែងជាមួយផ្នែកឧស្សាហកម្ម ដូចជាការបង្កើតអោយមានឱកាសចុះកម្មសិក្សានៅក្នុងកម្មវិធីសិក្សា។ ក៏ប៉ុន្តែយើងត្រូវតែដឹងថាយុទ្ធសាស្រ្តនេះនឹងទំនងជាកាត់បន្ថយការជំរុញនិស្សិតអោយធ្វើការស្រាវជ្រាវ។ ដូច្នេះអ្វីដែលត្រូវជំនះធ្វើ គឺការរួមបញ្ចូលភាពអាជីពនិងការស្រាវជ្រាវរួមគ្នាទៅក្នុងកម្មវិធីសិក្សាដើម្បីបង្កើតអោយមានជំរើសពីរសំរាប់ការងារនាពេលអនាគត។

| |
|---|
| អនុសាសន៍ទីបី<br><br>ប្រែក្លាយបរិញ្ញាបត្រជាន់ខ្ពស់ជាលំដាប់អន្តរជាតិ |

នាពេលបច្ចុប្បន្ន អនុសាសន៍របស់យើង គឺធ្វើយ៉ាងណាប្រែក្លាយបរិញ្ញាបត្រជាន់ខ្ពស់ក្លាយជាលំដាប់អន្តរជាតិ។ វាជាការផ្តល់ ឱកាសដើម្បីទាក់ទាញសិស្សបរទេស អ្នកស្រាវជ្រាវ អ្នកជំនាញ ក៏ដូចជាសាស្រ្តាចារ្យ។ លើសពីនេះទៅទៀត វាក៏ធ្វើអោយប្រសើរឡើងមាតិការនៃកម្មវិធីបណ្តុះបណ្តាលអោយទៅជាលំដាប់ស្តង់ដាអន្តរជាតិ។ ការបង្កើតបរិញ្ញាបត្រជាន់ខ្ពស់រួមគ្នាជាមួយដៃគូរអឺរ៉ុបគឺជាដំណោះស្រាយមួយដែលអាចធ្វើទៅបាន។

| |
|---|
| អនុសាសន៍ទីបួន<br><br>ការកសាងសមត្ថភាពសំរាប់គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក |

ភាគច្រើននៃសាកលវិទ្យាល័យនៅកម្ពុជាជួបបញ្ហាខ្វះខាតនូវសាស្រ្តាចារ្យ និងបុគ្គលិកធ្វើការពេញម៉ោង។ សមាមាត្រចំនួនគ្រូដែលធ្វើការពេញម៉ោងមានចំនួនតិចតួចធៀបទៅនឹងចំនួនបុគ្គលិកបង្រៀនទាំងអស់ ហើយមានអ្នកដែលមានសញ្ញាបត្របណ្ឌិត(មកពីក្រៅប្រទេស)តែពីរបីនាក់ប៉ុណ្ណោះ។ ជាងនេះទៅទៀត សាកលវិទ្យាល័យមិនត្រូវបានអនុញ្ញាតអោយតែងតាំងសាស្រ្តាចារ្យពេញម៉ោងឡើយ។ មានតែក្រសួងអប់រំទេ ដែលត្រូវអនុញ្ញាតអោយជ្រើសរើសសាស្រ្តាចារ្យពេញម៉ោង (ព្រះរាជក្រឹត្យ)។ និយាយជាទូទៅ កង្វះបទបញ្ញត្តច្បាស់លាស់ទាក់ទងទៅនឹងការវិវត្តនៃមុខរបរផ្នែកសិក្សាធិការគឺជាចំនុចគន្លឹះ (ជាទូទៅអវិជ្ជមាន)។ ចំនុចនេះប៉ះពាល់ទៅដល់ការដឹកនាំលើនិក្ខេបទនិស្សិតថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ ជាងនេះទៅទៀត ការបោះពុម្ពផ្សាយរបស់អ្នកស្រាវជ្រាវ ឬសាស្រ្តាចារ្យមិនឆ្លើយតមទៅនឹងស្តង់ដាអន្តរជាតិឡើយ។

ដើម្បីជាការលើកទឹកចិត្តដល់ការបោះពុម្ពលទ្ធផលនៃការស្រាវជ្រាវនៅក្នុងព្រឹត្តិបត្របោះពុម្ពផ្សាយអន្តរជាតិ រាល់ការជ្រើសរើស ការតម្លើងឋានៈដើម្បីទទួលបានដំណែងផ្នែកបង្រៀននៅតាមសាកលវិទ្យាល័យ (គ្រូបង្រៀន ជំនួយការសាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ) ត្រូវយោងទៅតាមប្រវត្តិល្អនៃការបោះពុម្ពផ្សាយជាមួយនឹងលក្ខណៈវិនិច្ឆ័យ (ឧទាហរណ៍ លទ្ធផលការសិក្សា បទពិសោធន៍អាជីព បណ្តាញទំនាក់ទំនងជាមួយសហគមន៍វិទ្យាសាស្ត្រជាតិ និងអន្តរជាតិ)។

| |
|---|
| អនុសាសន៍ទីប្រាំ<br><br>បង្កើតអោយមានស្តង់ដាគុណភាពតែមួយរវាងសាកលវិទ្យាល័យ (ឯកជន និងសាធារណៈ) |

មានប្រភេទសាកលវិទ្យាល័យជាច្រើននៅកម្ពុជាទាំងសាកលវិទ្យាល័យឯកជន និងសាធារណៈ។ យោងតាមការយល់ឃើញរបស់និស្សិត

ការដឹងពីអ្វីជាតម្លៃនៃសញ្ញាបត្រដែលផ្តល់ដោយក្របខណ្ឌសាកលវិទ្យាល័យមួយជារឿងសំខាន់។កម្មវិធីថ្នាកបណ្ឌិត

និងមុខវិជ្ជាសិក្សាគួរត្រូវបានធ្វើអោយមានសុខដុមតាមរយៈការបង្កើតអោយមានសាលាបណ្តុះបណ្តាលថ្នាក់បណ្ឌិតសំរាប់ស្ថាប័នឧត្តមសិក្សាដែលមានផ្តល់ជូននូវសញ្ញាបត្របណ្ឌិត។ នៅកំរិតបរិញ្ញាបត្រជាន់ខ្ពស់ និងបរិញ្ញាបត្រ

ការបង្កើតកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ថ្មីៗ អាចឆ្លើយតបទៅនឹងស្តង់ដាររួម និងតម្រូវការនានា។

| |
|---|
| អនុសាសន៍ទីប្រាំមួយ<br><br>បង្កើនភាពជាដៃគូ រវាង ឯកជន និងសាធារណៈ |

មានហេតុផលជាច្រើនដែលអាចបញ្ជាក់ថាស្ថាប័នឧត្តមសិក្សាគួរតែបង្កើតអោយមានភាពជាដៃគូរជាមួយផ្នែកឯកជនអោយកាន់តែរឹងមាំ៖ ហេតុផលទាំងនោះរួមមាន ការសំរួលដល់ការចុះកម្មសិក្សារបស់និស្សិត

បង្កើតមុខវិជ្ជាសិក្សាដែលឆ្លើយតបទៅនឹងការរំពឹងទុកក្នុងអាជីពការងារ ការចូលរួមរបស់អ្នកមានជំនាញអាជីពដែលមានចំនេះដឹងថ្មីៗនៅក្នុងវិស័យដែលជាក់លាក់ណាមួយក្នុងវគ្គបណ្តុះបណ្តាល។

ជាងនេះទៅទៀត និស្សិតអាចជោគជ័យក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ហើយក្នុងពេលជាមួយគ្នាធ្វើការពេញម៉ោងនៅក្នុងក្រុមហ៊ុន ក៏ប៉ុន្តែករណីយបែបនេះស្ទើរតែមិនអាចទៅរួចសំរាប់កាសិក្សាកំរិតបណ្ឌិត។

ការរៀនថ្នាក់បណ្ឌិតត្រូវបានគេទទួលស្គាល់ជាយូរមកហើយថាជាការធ្វើការពេញម៉ោង ហើយដែលទាមទារនូវលក្ខខណ្ឌមួយចំនួនដើម្បីបញ្ចប់ថ្នាក់បណ្ឌិតក្នុងរយៈពេលបីឆ្នាំ។ លក្ខខណ្ឌទីមួយគឺត្រូវទទួល

បានចំណូលតាមរយៈប្រព័ន្ធអាហាររូបករណ៍ដើម្បីក្លាយជាបេក្ខជនបណ្ឌិតពេញម៉ោង។

ក្រសួងគួរតែលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជនមួយចំនួនដើម្បីផ្តល់ជាថវិការដល់បេក្ខជនបណ្ឌិតដែលមានសក្តានុពលជាអ្នកស្រាវជ្រាវវ័យក្មេងដើម្បីធ្វើការស្រាវជ្រាវលើប

ញ្ហាមួយចំនួនដែលទាក់ទងនឹងចំណាប់អារម្មណ៍របស់ក្រុមហ៊ុន។

| |
|---|
| អនុសាសន៍ទីប្រាំពីរ<br><br>បង្កើតនាយកស្រាវជ្រាវជាមួយនឹងយុទ្ធសាស្ត្រច្បាស់លាស់ និង លក្ខខណ្ឌនៃសេចក្តីយោង |

ការបង្កើតយុទ្ធសាស្ត្រស្រាវជ្រាវរឹងមាំគួរតែត្រូវបង្កើតឡើងសំរាប់សាកលវិទ្យាល័យនានានៅកម្ពុជា។ គោលដៅនេះគឺដូចគ្នាទៅនឹងអនុសាស្រ្តទី៤។ នៅកម្ពុជា ការជំរុញលើកទឹកចិត្តដល់ការបង្កើតគម្រោងស្រាវជ្រាវ

គឺនៅមានសភាពទន់ខ្សោយដោយសារតែ៖

ទី១៖ ស្ថានភាពវិជ្ជាជីវៈ និងប្រាក់បៀវត្ស គឺមិនបានពឹងផ្អែកទៅលើកំរិតសិក្សា ឬការស្រាវជ្រាវ និងការវិនិយោគផ្នែកវិទ្យាសាស្ត្រនោះទេ។

ទី២៖ សាកលវិទ្យាល័យមិនមានសិទ្ធក្នុងការតែងតាំងសាស្ត្រាចារ្យពេញម៉ោងដោយខ្លួននោះឡើយ។

ទី៣៖ ដើម្បីទទួលបានប្រាក់ខែច្រើន សាស្ត្រាចារ្យត្រូវការបង្រៀនច្រើនម៉ោង។

ក្រសួងកំពុងតែរៀបចំបង្កើតលក្ខខណ្ឌនៃសេចក្តីយោងសំរាប់ដំណែងនាយកស្រាវជ្រាវនៅគ្រប់សាកលវិទ្យាល័យទាំងអស់។ តំណែងនេះ នឹងលេចចេញជារូបរាងនាពេលឆាប់ៗ។

| |
|---|
| អនុសាសន៍ទីប្រាំបី |

ផ្សារភ្ជាប់បេក្ខជនបណ្ឌិតទៅនឹងការស្រាវជ្រាវ

បេក្ខជនបណ្ឌិតគួរតែអាចក្លាយជាអ្នកស្រាវជ្រាវពេញម៉ោង ហើយគោលបំណងរបស់ពួកគេគឺធ្វើការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រវិទ្យាសាស្ត្រដែលមានឈ្មោះល្បី។ ក៏ប៉ុន្តែព្រឹត្តិបត្រល្បីៗទាំងនោះមានតម្រូវការច្រើនពីសំណាក់អ្នកស្រាវជ្រាវដ៏ទៃ។ ហេតុនេះហើយ គ្រប់បេក្ខជនបណ្ឌិតទាំងអស់គួរតែលើកទឹកចិត្តអោយបោះពុម្ពឬផ្ញើរអត្ថបទស្រាវជ្រាវទៅកាន់ព្រឹត្តិបត្របោះពុម្ពផ្សាយអោយបានលឿនតាមតែអាចធ្វើទៅបាន ហើយចូលរួមក្នុងសិក្ខាសាលាអន្តរជាតិដើម្បីស្វែងយល់ពីស្តង់ដារនៃការស្រាវជ្រាវវិទ្យាសាស្ត្រលំដាប់អន្តរជាតិ។ ការសហការជាមួយដៃគូរអន្តរជាតិ ការចូលរួមជាមួយបណ្តាញស្រាវជ្រាវវិទ្យាសាស្ត្រ និងការចូលរួមណែនាំធ្វើនិក្ខេបទថ្នាក់បណ្ឌិតដល់និស្សិតកម្ពុជាជាមួយដៃគូរអន្តរជាតិ គួរតែត្រូវលើកទឹកចិត្ត។

អនុសាសន៍ទីប្រាំបួន

បង្កើតការសហការរវាងសាកលវិទ្យាល័យយ៉ាងហោចណាស់ត្រឹមកំរិត បណ្ឌិត

អនុសាស្រ្តចុងក្រោយនេះ ជាការបំពេញបន្ថែមទៅលើអនុសាស្រ្តទីប្រាំ។ ភាគច្រើននៃសាកលវិទ្យាល័យរបស់ប្រទេសកម្ពុជាមិនមានទំហំធំគ្រប់គ្រាន់ដើម្បីបង្កើតអោយមានកម្មវិធី ឬសាលាថ្នាក់បណ្ឌិតអោយមានប្រសិទ្ធិភាពនោះឡើយ។ ឧទាហរណ៍បញ្ហាបរិស្ថានអាចត្រូវបានធ្វើការស្រាវជ្រាវដោយបេក្ខជនបណ្ឌិតថ្នាក់សេដ្ឋកិច្ច ច្បាប់ ឬកសិកម្ម។ បេក្ខជនថ្នាក់បណ្ឌិតមកពីជំនាញផ្សេងគ្នាគួរតែព្យាយាមធ្វើការជាមួយគ្នាយ៉ាងហោចណាស់តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលរួមគ្នា។ ដោយសារតែការបញ្ជូលនិស្សិតថ្នាក់បណ្ឌិតមកពីសាកលវិទ្យាល័យតាមបណ្តារខេត្តដើម្បីមកចូលរួមវគ្គសិក្សានៅភ្នំពេញជាទៀងទាត់ពេលខ្លះត្រូវចំនាយច្រើន សាកលវិទ្យាល័យរបស់កម្ពុជាគួរតែប្រើប្រាស់អោយបានច្រើននូវបរិក្ខារបំរើដល់ការសិក្សាពីចំងាយ ដើម្បីចែករំលែកកាតាឡុកមុខវិទ្យាសិក្សាជាមួយសាកលវិទ្យាល័យដ៏ទៃ។ ភាគច្រើននៃថវិការសំរាប់ការស្រាវជ្រាវត្រូវស្នើរឡើងតាមរយៈការប្រកាស់កំរិតជាតិ ឬអន្តរជាតិ។ វាស្ទើរតែមិនអាចទៅរួចដើម្បីទទួលបានជោគជ័យលើការប្រកាស់ផ្តល់ថវិការទាំងនោះប្រសិនបើយើងមិនមែនជាសមាជិកនៃក្រុមសម្ព័ន្ធមួយ។ ក្នុងន័យនេះ សាកលវិទ្យាល័យនៅកម្ពុជាគួរតែកំនត់ប្រធានបទស្រាវជ្រាវរួមគ្នា ហើយបង្កើតសហគមន៍វិទ្យាសាស្រ្ត ឬសិក្ខាសាលាថ្នាក់ជាតិទៅលើប្រធានបទពហុជំនាញដូចជា ការអភិវឌ្ឍន៏សមុទ្រសំរាប់និរន្តរភាពនៃកំនើនពណ៌ខៀវដោយមានការជួយជ្រែងពីនាយកស្រាវជ្រាវរបស់សាកលវិទ្យាល័យ (សូមមើលអនុសាសន៍ទី៨)។

## ៣ កម្មវិធីសិក្សាថ្នាក់បណ្ឌិតជំនាញការគ្រប់គ្រងបរិស្ថាននិងធនធាន

សាលាបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតលើជំនាញបញ្ហាសមុទ្រនិងបរិស្ថាន អាចមាននិរន្តរភាពប្រសិនបើវាគ្របដណ្ដប់ទៅលើវិស័យស្រាវជ្រាវផ្សេងៗទៀត។ សំរាប់បេក្ខជនបណ្ឌិតដែលជ្រើសរើសយកជំនាញវិទ្យាសាស្រ្តសង្គម ដូចជា សេដ្ឋកិច្ច គ្រប់គ្រង ភូមិសាស្រ្ត និងច្បាប់ ប្លង់មុខវិជ្ជាសិក្សាគួរតែបញ្ចូលវិជ្ជាសិក្សារួមគ្នា និង មុខវិជ្ជាតាមជំនាញជាក់លាក់របស់ខ្លួន។

ខាងក្រោមនេះ យើងលើកឡើងពីមុខវិជ្ជាសិក្សាដែលអាចត្រូវបានបញ្ចូលក្នុងកាតាឡុកមុខកម្មវិធីសិក្សាថ្នាក់បណ្ឌិត ដែលចាំបាច់សំរាប់បេក្ខជនបណ្ឌិតក្នុងជំនាញវិទ្យាសាស្រ្តសង្គមដែលទាក់ទងនឹងបរិស្ថាន និងបញ្ហាសមុទ្រ។

**<u>មុខវិជ្ជាសិក្សាទាក់ទងនឹងវិធីសាស្រ្តដែលអាចដាក់បញ្ចូល</u>**

- វិធីសាស្រ្តស្រាវជ្រាវតាមបរិមាណវិធី និងគុណភាពវិធី
- វិធីសាស្រ្តស្រាវជ្រាវវិទ្យាសាស្រ្តសង្គម
- វិធីសាស្រ្តស្រាវជ្រាវថ្នាក់បណ្ឌិត
- ការសរសេរតាមបែបវិទ្យាសាស្រ្ត និងការទំនាក់ទំនង

**<u>មុខវិជ្ជាសិក្សាដែលអាចសិក្សាក្នុងជំនាញ៖</u>**

- ការប្រែលប្រួលអាកាសធាតុ និង ការបន្សាំខ្លួនរបស់មនុស្ស
- មូលដ្ឋានវិទ្យាសាស្រ្តអេកូឡូហ្ស៊ី
- ច្បាប់បរិស្ថាន
- ការគ្រប់គ្រងតំបន់ឆ្នេរនិងតំបន់ដែលត្រូវប្ញកបញ្ចូល

**<u>មុខវិជ្ជាតាមជំនាញ</u>**

- សេដ្ឋកិច្ច
    - សេដ្ឋកិច្ចកសិកម្ម និងនយោបាយទឹក
    - និរន្តរភាព និងវិធីសាស្រ្តវាយតម្លៃសេដ្ឋកិច្ច
    - វិធីសាស្រ្តគណនាសេដ្ឋកិច្ចស៊ីជម្រៅ
    - ហានិភ័យ និងភាពមិនប្រាកដប្រជា
    - ទ្រឹស្តីល្បែង និងទ្រឹស្តីនៃការសំរេចចិត្ត
- ច្បាប់
    - ច្បាប់អន្តរជាតិ
    - ច្បាប់នយោបាយធនធានធម្មជាតិ និងស្ថាប័ន
    - ច្បាប់វិនិយោគអន្តរជាតិ
- គ្រប់គ្រង
    - គ្រប់គ្រងហានិភ័យ

- គ្រប់គ្រងធនធានធម្មជាតិ
- គ្រប់គ្រងភាគីពាក់ព័ន្ធ
- វិនិយោគបៃតង
- ការគ្រប់គ្រង ការសង្គ្រោះបន្ទាន់ និងវិបត្តិ

Co-funded by the
Erasmus+ Programme
of the European Union

*គម្រោងនេះទទួលបានថវិការ និងការគាំទ្រពីសហភាពអ៊ឺរ៉ុប។ ការបោះពុម្ពផ្សាយនេះឆ្លុះបង្ហាញពីការយល់ឃើញផ្ទាល់របស់អ្នកនិពន្ធ*
*ហើយសហភាពអ៊ឺរ៉ុបមិនទទួលខុសត្រូវរាល់ការប្រើប្រាស់ព័ត៌មានដែលយកចេញពីរបាយការណ៍នេះឡើយ។*